ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ.....០១៩.........បទ.-សរ.ក.ណ.........

ថ្ងៃ អង្គារ ៩កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាធារណរដ្ឋកូរ៉េ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជូនដំណឹងដល់មន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទាំងអស់ឱ្យបានជ្រាបថា រដ្ឋាភិបាលកូរ៉េតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញ Public Management និង Public Sector Reforms សម្រាប់ឆ្នាំសិក្សា២០២០នៅសាធារណរដ្ឋកូរ៉េ។

ចំពោះមន្ត្រីដែលមានបំណងដាក់ពាក្យស្នើសុំអាហារូបករណ៍ខាងលើ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

១.ត្រូវមានបទពិសោធការងារយ៉ាងតិច២ឆ្នាំ

២.បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ(សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល)

៣.មានការអនុញ្ញាតដោយប្រធានអង្គភាពក្នុងការដាក់ពាក្យស្នើសុំអាហារូបករណ៍

៤.អាចនិយាយនិងសរសេរភាសាអង់គ្លេសបានល្អ

៥.ត្រូវមានអាកប្បកិរិយាល្អ និងម៉ឺងម៉ាត់ ក្នុងការសម្របខ្លួនទៅនឹងបរិយាកាសរស់នៅ និងស្វែងយល់អំពីវប្បធម៌នៃសាធារណរដ្ឋកូរ៉េ

៦.ឯកសារតម្រូវការរបស់KOICA

-ត្រូវមានលិខិត១ច្បាប់ដែលមានការយល់ព្រម (Recommendation)ពីប្រធានអង្គភាព

-ឯកសារតម្រូវការរបស់សាកលវិទ្យាល័យ។

បេក្ខជនដែលមានចំណាប់អារម្មណ៍និងបំពេញលក្ខខណ្ឌខាងលើ សូមចូលទៅកាន់គេហទំព័រ http://www.koica.go.kr/khm_en/7882/subview.do ? ឬ Tel: 023 964 150/1/3 ឬ E-mail: koicascholar@gmail.com ដើម្បីទាញយកពាក្យស្នើសុំ និងធ្វើការបំពេញពាក្យ ដោយភ្ជាប់ជាមួយនូវព្រឹត្តិបត្រពិន្ទុផ្លូវការ លិខិតបញ្ជាក់ការសិក្សា ឬសញ្ញាបត្រថតចម្លងផ្លូវការ លិខិតឆ្លងដែនថតចម្លង រួចបញ្ជូនមកនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល ឱ្យបានមុនថ្ងៃ**ទី២០ ខែកក្កដា ឆ្នាំ២០២០** ដើម្បីនាយកដ្ឋានពិនិត្យ និងរៀបចំទាន់ពេលវេលាក្នុងការធ្វើសម្ភាស។

**បញ្ជាក់:** ចំពោះមន្ត្រីដែលបានជាប់អាហារូបករណ៍ខាងលើ ត្រូវធ្វើកិច្ចសន្យាចំនួន១ច្បាប់ ដើម្បីបម្រើការងារឱ្យក្រសួងរយៈពេល៥ឆ្នាំ បន្ទាប់ពីបញ្ចប់សិក្សានៅសាធារណរដ្ឋកូរ៉េ (ដូចមានលិខិតកិច្ចសន្យាភ្ជាប់ជូន)។

អាស្រ័យហេតុនេះ សូមមន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទាំងអស់ជ្រាបជាព័ត៌មាន។

**ត.ប.រដ្ឋមន្ត្រី**
**អគ្គនាយកនៃរដ្ឋបាល**

**ជឹងលី ស៊ីនិច**

**កន្លែងទទួល:**
- -ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- -គ្រប់អគ្គនាយកដ្ឋាន/អគ្គាធិការដ្ឋាន/វិទ្យាស្ថានជាតិ
- -និយ័តករទូរគមនាគមន៍កម្ពុជា
- -នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- -គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត
- -ការិយាល័យព័ត៌មាន
  "ដើម្បីផ្សព្វផ្សាយ"
- -ឯកសារ-កាលប្បវត្តិ

**ព័ត៌មានបន្ថែម:**
*សូមទំនាក់ទំនងការិយាល័យបណ្ដុះបណ្ដាល*
-០១១ ៣០១ ៦៧៨ /០៩៦ ៤៤៤ ៧៣៣៩